# សិទ្ធិរបស់ជនរងគ្រោះក្នុងសវនាការអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ការផ្តល់យុត្តិធម៌តម្រូវឱ្យមានតុល្យភាពរវាងសិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធិរបស់ជនរងគ្រោះ។ នៅប្រទេសកម្ពុជា សិទ្ធិរបស់ជនរងគ្រោះនៃករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានធានាដោយច្បាប់ជាតិ និងអន្តរជាតិ រួមទាំង សិទ្ធិទទួលបានយុត្តិធម៌ដោយគ្មានការរើសអើង និងទទួលបានសិទ្ធិតាមនីតិវិធីដូចគ្នានឹងភាគីផ្សេងទៀតនៅក្នុងសវនាការ។



## ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនរងគ្រោះក្នុងសវនាការអំពើហិង្សាទាក់ទងនឹងយេនឌ័រ

### បទប្បញ្ញត្តិ និងបទដ្ឋានអន្តរជាតិ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ក.អ.ស.ព.ន)

- មាត្រា ៣៖ សិទ្ធិស្មើភាពគ្នារវាងបុរស និងស្ត្រី
- មាត្រា ១៤៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ យោងតាមគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សិទ្ធិទទួលបានភាពស្មើគ្នាចំពោះមុខច្បាប់ និងសាលាជម្រះក្តីធានាបាននូវការទទួលបានភាពស្មើគ្នា និងសមភាពចំពោះមុខច្បាប់ ព្រមទាំងធានាថាភាគីនៃដំណើរការនីតិវិធីត្រូវបានប្រព្រឹត្តដោយគ្មានការរើសអើង (គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ,សេចក្តីពន្យល់ទូទៅលេខ ៣២)
- មាត្រា ១៦៖ ការទទួលស្គាល់ជាបុគ្គលិកលក្ខណៈគតិយុត្តិ

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

- មាត្រា ៥ (ក)៖ កាតព្វកិច្ចរដ្ឋក្នុងការលុបបំបាត់នូវផ្នត់គំនិត និងវប្បធម៌នៃសេចក្តីលម្អៀង
- មាត្រា ១៥ (១)៖ សមភាពរវាងបុរស និងស្ត្រីចំពោះមុខច្បាប់

គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានសំណង និងការជួសជុលការខូចខាត៖ (សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ ៦០/១៤៧)

- មាត្រា ១០៖ ការប្រព្រឹត្តចំពោះជនរងគ្រោះជាមនុស្សជាតិ និងគោរពសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្ស ព្រមទាំងអនុសាសន៍សម្រាប់រដ្ឋក្នុងការធានាពីសុវត្ថិភាពបូរណភាពរាងកាយ និងផ្លូវចិត្ត រួមទាំងឯកជនភាពរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ។
- មាត្រា ១២៖ ភាពចាំបាច់សម្រាប់រដ្ឋគឺផ្តល់នូវជំនួយសមស្របដល់ជនរងគ្រោះដែលកំពុងស្វែងរកយុត្តិធម៌។

### បទប្បញ្ញត្តិជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- មាត្រា ៣១៖ ប្រជាពលរដ្ឋទាំងអស់មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងទទួលបានសិទ្ធិ និងសេរីភាពដូចគ្នាទាំងអស់ដោយមិនមានការរើសអើង។
- មាត្រា ៤៥៖ លុបបំបាត់ចោលរាល់ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

- មាត្រា ៣១៖ សិទ្ធិស្មើភាពគ្នាក្នុងការទទួលបានអ្នកការពារតាមផ្លូវច្បាប់សម្រាប់ជនរងគ្រោះ និងជនមុខសញ្ញា

ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

- មាត្រា ១៤៤៖ សិទ្ធិទទួលបានអ្នកបកប្រែ
- មាត្រា ១៥០៖ សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានជំនួយផ្នែកច្បាប់ និងត្រូវបានស្តាប់ចម្លើយដោយមានវត្តមានមេធាវីរបស់ពួកគេ

ក្រមសីលធម៌តុលាការកម្ពុជា

- មាត្រា ៣១៖ ចៅក្រមទាំងអស់មានកាតព្វកិច្ចវិនិច្ឆ័យសំណុំរឿងដោយមិនមានការរើសអើង



### គោលការណ៍ និងសេចក្តីណែនាំស្តីពីការទទួលបានជំនួយផ្នែកច្បាប់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

(សេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ ៦៧/១៨៧)

គោលការណ៍៤៖ អនុសាសន៍ថារដ្ឋត្រូវផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយមិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ឡើយ

សេចក្តីណែនាំ៩៖ អនុសាសន៍ថារដ្ឋត្រូវចាត់វិធានការសមស្របដើម្បីធានាថាស្ត្រីត្រូវទទួលបានជំនួយផ្នែកច្បាប់ ដែលរួមមានការផ្តល់នូវអ្នកការពារផ្នែកច្បាប់ ការប្រឹក្សាយោបល់ សេវាគាំទ្រពីតុលាការក្នុងរាល់ដំណើរការនីតិវិធីច្បាប់ដល់ជនរងគ្រោះជាស្ត្រី ដើម្បីធានាថា ទទួលបានយុត្តិធម៌ ចៀសវាងទទួលរងគ្រោះផ្ទួន និងសេវាផ្សេងៗទៀត ដូចជាបកប្រែឯកសារតាមការស្នើសុំ ឬជាការតម្រូវ។

## ភាពអាចទទួលបាន

ជនរងគ្រោះនៃករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ មានសិទ្ធិទទួលបានយុត្តិធម៌ចំពោះករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបានប្រព្រឹត្តមកលើខ្លួន។ ដូចនេះ ទាមទាឲ្យមានលទ្ធភាពទទួលបាននូវយន្តការ និងនីតិវិធីរបស់តុលាការ។ ជាការសំខាន់ណាស់ដែលរាល់ការប្រាស្រ័យទាក់ទង ឬឧបសគ្គនានាត្រូវដកចេញ ដើម្បីឱ្យជនរងគ្រោះអាចចូលរួមក្នុងដំណើរការសវនាការពេញលេញប្រកបដោយប្រសិទ្ធភាព។

ដូច្នេះ តុលាការត្រូវតែប្រាប់ដល់ជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេជាភាសាដែលពួកគេយល់បាន និងប្រើប្រាស់វាក្យស័ព្ទដែលសមស្របនឹងអាយុ និងកម្រិតនៃការអប់រំរបស់ពួកគេ។



## ការទទួលបានជំនួយផ្នែកច្បាប់

នៅក្នុងប្រទេសមួយចំនួនរួមមានកម្ពុជា ជំនួយផ្នែកច្បាប់អាចត្រូវបានផ្តល់ឱ្យ ប៉ុន្តែមិនមែនជាកាតព្វកិច្ចតម្រូវសម្រាប់ជនរងគ្រោះពីបទល្មើសដែលចង់ចូលរួមដំណើរការនីតិវិធីជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ បទដ្ឋានអន្តរជាតិលើកទឹកចិត្តឱ្យរដ្ឋផ្តល់ជំនួយផ្នែកច្បាប់ក្នុងកម្រិតអតិបរមាដែលអាចធ្វើទៅបាន រួមទាំងជនរងគ្រោះពីបទល្មើសនោះផង។

រដ្ឋគួរតែចាត់វិធានការសមស្របបន្ថែមទៀត ដើម្បីធានាសិទ្ធិរបស់ស្ត្រីក្នុងការទទួលបានជំនួយផ្នែកច្បាប់ រួមមានផ្តល់មេធាវីការពារ ការផ្តល់យោបល់ និងសេវាគាំទ្ររបស់តុលាការ នៅក្នុងដំណើរការនីតិវិធីច្បាប់ ដើម្បីជនរងគ្រោះជាស្ត្រីទទួលបានយុត្តិធម៌។

## មិនមានការរើសអើងក្នុងសវនាការ




ផ្នត់គំនិត និងភាពលម្អៀងផ្អែកលើយេនឌ័រនៅក្នុងប្រព័ន្ធយុត្តិធម៌រារាំងជនរងគ្រោះជាស្ត្រីក្នុងការទទួលបានយុត្តិធម៌។ ភាសាអាសអាភាស ប្រមាថមើលងាយ និងបន្ទាបបន្ថោក គឺជាការរំលោភបំពានលើសិទ្ធិមិនរើសអើង សិទ្ធិទទួលបានការការពារផ្លូវច្បាប់ និងភាពស្មើគ្នាចំពោះមុខតុលាការ។

យោងទៅតាមបទដ្ឋានអន្តរជាតិ តុលាការដែលរួមបញ្ចូលអ្នកវិជ្ជាជីវៈទាំងអស់នៃប្រព័ន្ធយុត្តិធម៌ (មេធាវី ព្រះរាជអាជ្ញា ក្រឡាបញ្ជី ។ល។) មានកាតព្វកិច្ចធានាគ្រប់នីតិវិធីច្បាប់ទាំងអស់ដែលពាក់ព័ន្ធនឹងការចោទប្រកាន់នៃករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រប្រឆាំងនឹងស្ត្រីត្រូវធ្វើឡើងដោយគិតគូរយកចិត្តទុកដាក់លើយេនឌ័រមិនលម្អៀង និងយុត្តិធម៌ ហើយមិនរងឥទ្ធិពលពីផ្នត់គំនិតយេនឌ័រ ឬការបកស្រាយបែបរើសអើងនៃបទប្បញ្ញត្តិច្បាប់។




## សិទ្ធិដឹងពុកស្តាង និងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់

ច្បាប់អន្តរជាតិបានចែងអំពីសមភាពរបស់ភាគីទាំងអស់នៅពេលជំនុំជម្រះ។

សមភាពភាពចំពោះមុខច្បាប់មានន័យថា "នៅគ្រប់នីតិវិធីទាំងអស់ត្រូវបានផ្តល់ឱ្យដូចគ្នាទាំងអស់ដល់គ្រប់ភាគី លុះត្រាតែមានកំណត់ដោយច្បាប់ដែលមានហេតុផលត្រឹមត្រូវ និងសត្យានុម័តដោយមិនបាត់បង់អត្ថប្រយោជន៍ណាមួយ ឬភាពអយុត្តិធម៌ផ្សេងទៀតឡើយ"។ (គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅ លេខ ៣២)

ដូច្នេះចៅក្រម មានតួនាទីសំខាន់ក្នុងការធានានូវសមភាពចំពោះមុខច្បាប់ពីព្រោះគាត់ជាអ្នកគ្រប់គ្រងក្នុងដំណើរការសវនាការ។

## សេចក្តីសម្រេចយោងតាមច្បាប់

ចៅក្រមត្រូវវាយតម្លៃអង្គហេតុនៃសំណុំរឿងយោងតាមច្បាប់។ កាតព្វកិច្ចនេះ កើតចេញពីគោលការណ៍ជាមូលដ្ឋាននៃភាពស្របច្បាប់ដែលមានចែងទាំងក្នុងច្បាប់អន្តរជាតិ និងច្បាប់ជាតិ។

យុត្តិធម៌ត្រូវបានបង្ហាញ ជនជាប់ចោទត្រូវតែផ្តន្ទាទោសសម្រាប់អំពើដែលខ្លួនបានប្រព្រឹត្ត ដែលកំណត់ដោយច្បាប់។ ប្រសិនបើជនជាប់ចោទត្រូវបានផ្តន្ទាទោសតិចមិនសមាមាត្រនឹងអំពើល្មើសដែលពួកគេបានប្រព្រឹត្ត នោះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះ។

ចៅក្រមត្រូវពន្យល់ទាំងអង្គហេតុ និងអង្គច្បាប់ដែលសាលក្រមព្រហ្មទណ្ឌបានសម្អាង ដើម្បីឱ្យយល់អំពីមូលហេតុ និងរបៀបដែលសាលក្រមត្រូវបានសម្រេច និងមូលហេតុដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធ ដើម្បីជៀសវាងសាលក្រមដែលលម្អៀង និងរើសអើង។

ប្រភព៖ UN Docs CCPR/C/GC/៣២; CEDAW/C/GC/៣៣; CEDAW/C/GC/៣៥; CCPR/C/GC/៣២; A/RES/៦៥/២២៨


CC BY NC SA